ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-សជណ/ 11-02-15/អ-បល-P.111

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ: ១២៨៣ អឌល.អក.រប

# សេចក្ដីជូនដំណឹង
## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថាអគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិកបណ្ដោះអាសន្ន ចំនួន ០១ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជាដូចខាងក្រោម:

*- **លក្ខណៈសម្បត្តិបេក្ខជន** :

- បេក្ខជនភេទប្រុស,មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ (គិតត្រឹមថ្ងៃឈប់ទទួលពាក្យ)
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត)ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** :សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជាឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥

ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា